# សេចក្តីសម្រេច

## ស្តីពីការកំណត់បញ្ជីថ្លៃលក់អគ្គិសនីតាមយន្តការកែតម្រូវថ្លៃលក់តាមថ្លៃប្រេងម៉ាស៊ូត ឱ្យសេវាករ ហ៊ាង ពៅ ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់ទូទៅ នៅឃុំចំបក់ និងឃុំឬស្សីកែវ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ

## អាជ្ញាធរអគ្គិសនីកម្ពុជា

- អនុវត្តតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១
- អនុវត្តតាមការកំណត់របស់អនុក្រឹត្យ លេខ៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី
- អាជ្ញាប័ណ្ណរួមលេខ២១៧.ឯអ ដែលបានចេញឱ្យលោក ហ៊ាង ពៅ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៨
- ឯកសារស្នើសុំកំណត់បញ្ជីថ្លៃលក់អគ្គិសនីរបស់លោក ហ៊ាង ពៅ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៩
- យោងឯកសារគណនា វិភាគ វាយតម្លៃរបស់នាយកដ្ឋានជំនាញនៃអាជ្ញាធរអគ្គិសនីកម្ពុជា
- យោងការពិគ្រោះយោបល់សាធារណៈ ចាប់ពីថ្ងៃទី១៣ ខែមករា ដល់ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១០
- យោងតាមការអនុម័តរបស់សម័យប្រជុំអាជ្ញាធរអគ្គិសនីកម្ពុជាលើកទី១៧៨ នាថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១០

## សម្រេច

**ប្រការ ១ ~**

កំណត់បញ្ជីថ្លៃលក់អគ្គិសនីឱ្យសេវាករ ហ៊ាង ពៅ កាន់អាជ្ញាប័ណ្ណលេខ២១៧.ឯអ ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់ទូទៅ នៅឃុំចំបក់ និងឃុំឬស្សីកែវ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ដោយកំណត់បញ្ជីថ្លៃលក់ជាតារាងប្រែប្រួលតាមថ្លៃប្រេងម៉ាស៊ូត ដែលមានកំណត់ដូចខាងក្រោម÷

| | | | | | |
|---|---|---|---|---|---|
| ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន) | 360 | 425 | 490 | 555 | |
| ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉) | 2,100 | 2,200 | 2,300 | 2,400 | |
| ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន) | 620 | 685 | 750 | 815 | |
| ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉) | 2,500 | 2,600 | 2,700 | 2,800 | |
| ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន) | 880 | 945 | 1,010 | 1,075 | |
| ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉) | 2,900 | 3,000 | 3,100 | 3,200 | |

| | | | | | |
|---|---|---|---|---|---|
| ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន) | 1,140 | 1,205 | 1,270 | 1,335 | |
| ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉) | 3,300 | 3,400 | 3,500 | 3,600 | |
| ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន) | 1,400 | 1,465 | 1,530 | 1,595 | |
| ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉) | 3,700 | 3,800 | 3,900 | 4,000 | |
| ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន) | 1,660 | 1,725 | 1,790 | 1,855 | |
| ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉) | 4,100 | 4,200 | 4,300 | 4,400 | |

## ប្រការ ២ ~

តារាងថ្លៃលក់ដែលប្រែប្រួលតាមថ្លៃប្រេងម៉ាស៊ូតខាងលើនេះ ត្រូវអនុវត្តតាមល័ក្ខខ័ណ្ឌដែលមានកំណត់ដូចខាងក្រោម ÷

**១-** តារាងថ្លៃលក់ដែលប្រែប្រួលតាមថ្លៃប្រេងឥន្ធនៈនេះ គឺជាការកំណត់បញ្ជីថ្លៃលក់ជាចង្កោមមួយដែលប្រែប្រួលទៅតាមកម្រិតថ្លៃប្រេងឥន្ធនៈ។

**២-** ការប្តូរពីកម្រិតថ្លៃមួយទៅកម្រិតថ្លៃមួយទៀត នៅក្នុងប្រការ១ខាងលើ ត្រូវមានការសម្រេចឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីអាជ្ញាធរអគ្គិសនីកម្ពុជាអាចត្រួតពិនិត្យលើថ្លៃប្រេងឥន្ធនៈថាតើបានប្រែប្រួលត្រឹមត្រូវដែលអាចអនុញ្ញាតឱ្យប្តូរពីថ្លៃមួយទៅថ្លៃមួយទៀតបាន ឬនៅ។

**៣-** នៅពេលដែលថ្លៃប្រេងម៉ាស៊ូតកើនឡើង ឬថយចុះជាក់ស្តែងដល់កម្រិតជាក់លាក់មួយដែលមានកំណត់នៅក្នុងតារាងនៃប្រការ១ អាជ្ញាធរអគ្គិសនីកម្ពុជា អ្នកកាន់អាជ្ញាប័ណ្ណ ឬអ្នកប្រើប្រាស់មានសិទ្ធស្នើសុំកែសម្រួលអត្រាថ្លៃលក់ ពីកម្រិតមួយទៅកម្រិតមួយទៀតបាន។

**៤-** អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវពត៌មាន អំពីការប្រែប្រួលថ្លៃប្រេងម៉ាស៊ូតដែលរួមមានវិក្កយបត្រទិញប្រេងឥន្ធនៈពីប្រភពនានាជាក់ស្តែង។

**៥-** អាជ្ញាធរអគ្គិសនីកម្ពុជានឹងចេញលិខិតអនុញ្ញាតយល់ព្រម លើការស្នើសុំកែតម្រូវអត្រាថ្លៃលក់ក្នុងតារាងនៃប្រការ១ក្នុងរយៈពេលមិនហួស៣០ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំនិងទទួលបានឯកសារភ័ស្តុតាងគ្រប់គ្រាន់សម្រាប់ការកែសម្រួលកម្រិតថ្លៃលក់ក្នុងតារាងនេះ។ ការយល់ព្រមនេះមិនចាំបាច់ធ្វើការពិគ្រោះយោបល់សាធារណៈឡើយ។

## ប្រការ ៣ ~

តារាងថ្លៃលក់ដែលប្រែប្រួលតាមថ្លៃប្រេងម៉ាស៊ូតមានចែងក្នុងប្រការ១ខាងលើ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ រហូតដល់មានការកែសម្រួលឡើងវិញ ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ស្របតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៤ ~

សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តចំពោះអ្នកប្រើប្រាស់អគ្គិសនីគ្រប់ប្រភេទដែលឋិតក្នុងតំបន់ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីរបស់សេវាករ ហ៊ាង ពៅ ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់ទូទៅ នៅឃុំចំបក់ និងឃុំឬស្សីកែវ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ប៉ុណ្ណោះ។

**ប្រការ ៥ ៖**

សេវាករ ហ៊ាង ពៅ និងអ្នកប្រើប្រាស់អគ្គិសនីគ្រប់ប្រភេទដែលឋិតក្នុងតំបន់ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីរបស់សេវាករ ហ៊ាង ពៅ មានភារកិច្ចអនុវត្តតារាងបញ្ជីថ្លៃលក់អគ្គិសនីនេះឱ្យមានប្រសិទ្ធភាព។

**ប្រការ ៦ ៖**

សេវាករ ហ៊ាង ពៅ មានភារកិច្ចផ្សព្វផ្សាយអំពីខ្លឹមសារសេចក្តីសម្រេចនេះ ដល់អតិថិជនរបស់ខ្លួនគ្រប់ប្រភេទដែលពាក់ព័ន្ធ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**<u>ចម្លងជូន</u> :**

- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- សាលាខេត្តក្រចេះ
- មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តក្រចេះ
- សាលាស្រុកព្រែកប្រសព្វ
- សាលាឃុំចំបក់, សាលាឃុំឬស្សីកែវ

  “ដើម្បីជូនជ្រាប”
- សេវាករ ហ៊ាង ពៅ

  “ដើម្បីផ្សព្វផ្សាយ និងអនុវត្ត”
- ឯកសារ-កាលប្បវត្តិ